**ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ២៤៤ ខែ១០ឆ្នាំ២០១៣**

**ពាក្យគន្លឹះ៖** មនុស្សឃាដគិតទុកជាមុន, ពេលប្រព្រឹត្តមិនបាននៅទីតាំង, អនីតិជន, របាយការណ៍ប៉ូលីស, វិមតិសង្ស័យ។

**កាលបរិច្ឆេទ៖** សំណុំរឿងលេខ២៨៥(២០១២) សាលដីកាចេញថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៣។

**អង្គហេតុនិងការសម្រេច៖** ពិរុទ្ធជនចំនួន៧រូប (ម្នាក់អនីតិជនអាយុ១៥ឆ្នាំ) ត្រូវបានសាលា ដំបូងផ្តន្ទាទោសពីបទមនុស្សឃាតគិតទុកជាមុន (សាលក្រម៤៨ជចុះថ្ងៃទី១២ ខែឧសភាឆ្នាំ២០១១) និងបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមទាំងមូល។ សាលាឧទ្ធរណ៍ បានចេញសាលដីកាលេខ៤៦ក្រII ឆ្នាំ២០១២តម្កល់សាលក្រម និងសាលដីកាលេខ១០៤ក្រII ឆ្នាំ២០១២។ ពិរុទ្ធជនទាំងអស់ បានប្តឹងសាទុក្ខប្រឆាំងសាលដីកាលេខ១០៤ក្រII។ មេធាវីការពារ បានអះអាងថាកូនក្តីខ្លួនមិនបានប្រព្រឹត្ត អង្គហេតុមានវិមតិសង្ស័យ។ មហាអយ្យការអមតុលាការកំពូល បានសន្និដ្ឋានថា៖ ទទួលយកបណ្តឹងសាទុក្ខ និងស្នើបដិសេធសាលដីកាព្រហ្មទណ្ឌលេខ១០៤ក្រ II ចុះថ្ងៃទី២៤ ខែមេសាឆ្នាំ២០១២។

តុលាការកំពូល៖....យល់ឃើញថា*ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីកំណត់អង្គហេតុនៃបទល្មើស និងធាតុផ្សំនៃបទល្មើស លើជនជាប់ចោទម្នាក់ៗអោយបានច្បាប់លាស់ទេ។ ទាំងសាលាដំបូង ទាំងសាលាឧទ្ធរណ៍ ក្នុងការយល់ឃើញ ពុំឃើញមានបង្ហាញនូវអង្គហេតុស្ថាពរ ដែលកំណត់ថាជនត្រូវចោទម្នាក់ៗ មានសកម្មភាពយ៉ាងដូចម្តេចនៅក្នុងបទល្មើសនេះឡើយ ដូច្នេះសាលដីការបស់សាលាឧទ្ធរណ៍នេះ មានកំហុសរំលោភទៅលើមាត្រា៤១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ* (ទំ.៧)។

**សម្រេច៖**...បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២៨៥(២០១២) របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះឡើងវិញ។

**កំណត់សំគាល់៖** ក. តាំងពីក្នុងដំណាក់កាលសាលាឧទ្ធរណ៍ប្រពន្ធជនរងគ្រោះ បានដកពាក្យបណ្តឹង ដោយអះអាងថាពិរុទ្ធជនមិនបានប្រព្រឹត្តបទល្មើសមកលើប្តីខ្លួនទេ (មេធាវី)។ **ខ.** តាមខ្លឹមសារដកស្រង់ខាងលើ ដើម្បីកំណត់សកម្មភាពប្រព្រឹត្តនៃជនជាប់ចោទម្នាក់ ត្រូវផ្អែកលើអង្គហេតុស្ថាពរ ដើម្បីកំណត់ធាតុផ្សំបទល្មើស។ វាទាមទារនូវការបង្ហាញសកម្មភាពជាក់លាក់នៃអ្នកចូលរួមនីមួយៗ។ **គ.** តាំងពីថ្ងៃប្រព្រឹត្ត២០០៨ ដល់ឆ្នាំ២០១៣ មានរយៈពេល៥ឆ្នាំ។ សាលាឧទ្ធរណ៍នឹងជំនុំជម្រះជាថ្មី។ ក្នុងករណីមិនពេញចិត្តពិរុទ្ធជនអាចប្តឹងសាទុក្ខលើកទី២ ដែលតុលាការកំពូលនឹងសម្រេចពេញអង្គលើអង្គហេតុ និងអង្គច្បាប់។ ដូចនេះ ពិរុទ្ធជនត្រូវរងចាំពេលវេលាយូរទៀត។ តើមានវាសនាយ៉ាងណា? ចុះក្នុងករណីរកឃើញ ថាមិនបានប្រព្រឹត្ត តើអាជ្ញាធរ ឬជនណាទទួលខុសត្រូវសងខូចខាតដល់ពួកគេ? សូមតាមដាន!

**សំណួរអាចលើកឡើង៖** តើក្នុងករណីណា ដែលតុលាការកំពូលសម្រេចបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីសម្រេចជាថ្មី?

**អ្វីត្រូវអានបន្ថែម៖** ការទទួលខុសត្រូវចំពោះការកាត់សេចក្ដីខុស (wrongful conviction) ខ្លឹមសារសង្ខេបសាលក្រមលេខ៤៨ឆ្នាំ២០១១ និងសាលដីកាលេខ១០៤ឆ្នាំ២០១២។